ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តប៉ៃលិន**

-សំណុំរឿងព្រហ្មទណ្ឌលេខ ២៣៧

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ

១៦១/២៩.១២.២១

-ដំនុំជម្រះលេខ ៣៨/២៣.០៣.២២

-សាលក្រមលេខៈ ៥៤ -គ-

ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ប៉ៃលិន ថ្ងៃទី១៧ ខែ០៦ ឆ្នាំ២០២២

ក្រឡាបញ្ជី

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តប៉ៃលិន បានបើកសវនាការជាសាធារណៈនាថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ៣០ នាទីរសៀល ដោយមានសមាសភាពដូចតទៅ៖

## ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តប៉ៃលិន

## ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តប៉ៃលិន

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តប៉ៃលិន

## តំណាងអយ្យការ

លោក **ទេព ឃុនឆ័យ** ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តប៉ៃលិន

## ក្រឡាបញ្ជីសវនាការ

លោក **ហោ ពិសិទ្ធ** ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តប៉ៃលិន

## ដើម្បីជំនុំជម្រះ

[redacted] លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **រិទ្ធី** ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិ និងសញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តបាត់ដំបង បច្ចុប្បន្នកំពុងជាប់ពន្ធនាគារខេត្តប៉ៃលិន នៅលីវ ឪពុកឈ្មោះ [redacted] ចំរើន (រ) ម្តាយឈ្មោះ[redacted] ប្រាក់ (រ) ទោសពីមុនមាន ជាអនីតិជន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៧៩ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន។

ជាប់ចោទពីបទ **ជួញដូរ ,រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ ឆ្នាំ ជនជាតិ និងសញ្ជាតិខ្មែរ មុខរបរមន្ត្រីពន្ធនាគារ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រាកើត

សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន នៅលីវ ឪពុកឈ្មោះ [redacted]ចេក (រ) ម្តាយឈ្មោះ [redacted]ផេង (រ) ទោសពីមុនគ្មាន ជានីតិជន។ (ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៨១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តប៉ៃលិន។

ជាប់ចោទពីបទ ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] ជាមេធាវីប្រតិភូនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តប៉ៃលិន។

-លោកមេធាវី [redacted] មានការិយាល័យ តាំងនៅផ្ទះលេខ ១៩០ ក្រុមទី៤១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ។

## អង្គហេតុនៃរឿងមានដូចតទៅ៖

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ប៉ៃលិន,ថ្ងៃទី ០៧ ខែ ០៨ ឆ្នាំ២០២២
ហោ ពិសិដ្ឋ

កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៧ និង ០០ នាទី ស្ថិតនៅពន្ធនាគារខេត្តប៉ៃលិន ក្នុងភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កម្លាំងប្រឆាំងគ្រឿងញៀននៃអធិការដ្ឋាននគរបាលក្រុងប៉ៃលិន បានធ្វើការបង្ក្រាបបទល្មើសជាក់ស្តែង រក្សាទុក ,ជួញដូរ ,ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២ នាក់ រួមមានឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ១៦ ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted]ចិត្ត ភេទប្រុស អាយុ ២៨ ឆ្នាំ ជាតិខ្មែរ និងបានធ្វើការឆែកឆេរលើទណ្ឌិតឈ្មោះ [redacted] រិទ្ធី ឃើញថ្នាំញៀនចំនួន ០១ កញ្ចប់ធំរុំដោយស្កុតពណ៌ខ្មៅទម្ងន់ ៦៧,៣៥ ក្រាម (ថ្នាំសុទ្ធ) បម្រុងយកចូលទៅក្នុងពន្ធនាគារ។ ក្រោយសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងនាំជនសង្ស័យទៅធ្វើការសាកសួរ ជនសង្ស័យឈ្មោះ [redacted] រិទ្ធី បានឆ្លើយថា ថ្នាំញៀនចំនួន ០១ កញ្ចប់ធំខាងលើ គឺឈ្មោះ [redacted] ចិត្ត (មន្ត្រីពន្ធនាគារខេត្តប៉ៃលិន) ជាអ្នកប្រគល់ឱ្យខ្លួនដើម្បីយកចូលទៅក្នុងពន្ធនាគារខេត្តប៉ៃលិន។ បន្ទាប់មកសមត្ថកិច្ចជំនាញបានធ្វើការកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តប៉ៃលិន ដើម្បីចាត់ការតាមនីតិវិធី។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ២៧ ដ.ស.ព ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តប៉ៃលិន។

**បានឃើញ** ដីកាដំណោះស្រាយលេខ ៣៣០ ដ.ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តប៉ៃលិន។

**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ ៥៧ ត.ព្រ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២២ ។

# នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី បានឆ្លើយនាពេលសវនាការថា៖ នៅថ្ងៃកើតហេតុខ្លួន និងជនជាប់ឃុំផ្សេងទៀតព្រមទាំងមន្ត្រីពន្ធនាគារ បានយកសម្រាមទៅចោលនៅកន្លែងចាក់សម្រាមក្បែរពន្ធនាគារ។ នៅពេលដែលទៅចាក់សម្រាម ខ្លួនបានរើសប្រអប់មួយរាងដូចប្រអប់ទូរស័ព្ទដោយមានរុំស្កុតខ្មៅ ខ្លួនបានរើសប្រអប់នឹងដើរដល់ពាក់កណ្តាលផ្លូវក៏បានបោះប្រអប់នឹងចោល។ ក្រោយមកទៀតនៅពេលដែលមន្ត្រីពន្ធនាគារនាំជនជាប់ឃុំចូលទៅក្នុងពន្ធនាគារវិញ ខ្លួនក៏បានសុំមន្ត្រីពន្ធនាគារឈ្មោះ [redacted] កែវមុន្នី ចេញមកក្រៅដើម្បីទៅរើសប្រអប់ខ្មៅនោះវិញ ដោយខ្លួនបានប្រាប់ថា "សុំទៅលាងចានឱ្យមន្ត្រីពន្ធនាគារឈ្មោះ [redacted] ចិត្ត" តែតាមការពិត គឺខ្លួនទៅរើសប្រអប់ខ្មៅនោះទេ។ នៅពេលដែលខ្លួនទៅដល់កន្លែងដែលខ្លួនបានបោះចោលប្រអប់ខ្មៅនោះ ខ្លួនបានរើសយកមកវិញដោយមួរនឹងចង្កេះខោ។ នៅពេលចូលដល់ច្រកសុវត្ថិភាពមន្ត្រីឈ្មោះ [redacted] កែវមុន្នី បានសួរថា "ឯងទៅលាងចានឱ្យឈ្មោះ [redacted] ចិត្ត ម៉េចក៏លឿនម្ល៉េះ" នៅពេលនោះមន្ត្រីឈ្មោះ [redacted] កែវមុន្នី ក៏បានឆែកឆេរ ហើយរកឃើញប្រអប់ខ្មៅដែលខ្លួនមួរនឹងចង្កេះខោ ដោយបើកឃើញថ្នាំញៀន។ បន្ទាប់មកគាត់ក៏បានបញ្ជូនខ្លួនចូលទៅពន្ធនាគារ ដើម្បីធ្វើការសាកសួរ។ នៅពេលធ្វើការសាកសួរឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ហុង បានសួរខ្លួនថា "អញដឹងច្បាស់ណាស់មានគេប្រាប់ថា គេឃើញហ្អែងទៅយកថ្នាំញៀននៅផ្ទះឈ្មោះ [redacted] ចិត្ត ហ្អែងឆ្លើយឱ្យត្រង់មក បើមិនចឹងទេ ហ្អែងជាប់ម្ភៃសាមសិបឆ្នាំទៀតហើយ ហ្អែងយកថ្នាំញៀនពីឈ្មោះ វៀ ចិត្ត មែនអត់?" នៅពេលនោះ ខ្លួនភ័យពេកក៏ឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត តែម្តងទៅ។ ចំពោះរឿងនេះ ឈ្មោះ [redacted] ចិត្ត មិនបានពាក់ព័ន្ធនោះទេ ហើយគាត់ក៏មិនបានឱ្យខ្លួនទៅយកថ្នាំញៀនអីនោះដែរ គឺខ្លួនទៅយកប្រអប់នោះដោយខ្លួនឯង។

-តាមចម្លើយរបស់ឈ្មោះ [redacted] ចិត្ត នាពេលសវនាការបានឆ្លើយថា៖ កាលពីថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២១ នាពេលព្រឹក ខ្លួនបានសហការជាមួយមន្ត្រីការិយាល័យប្រតិបត្តិចំនួន ០២ នាក់ និងការិយាល័យបណ្តុះបណ្តាល និងអប់រំ ០២ នាក់ សរុបមន្ត្រីមានចំនួន ០៤ នាក់ និងជនជាប់ឃុំចំនួន ០៣ នាក់ទៀតដើម្បីទៅធ្វើអនាម័យនៅក្រៅរបងសុវត្ថិភាព។ លុះដល់ពាក់កណ្តាលផ្លូវប្រហែល ១០០ ម៉ែត្រ ខ្លួនបានប្រាប់ដល់មន្ត្រីដែលរួមដំណើរជាមួយថា ខ្លួនឡើងទៅមុនហើយ ទៅរកធ្វើម្ហូបក្លែម។ នៅពេលនោះ ជនជាប់ឃុំបញ្ជូនចូលក្នុងរបងសុវត្ថិភាពអស់ហើយ។ ចំពោះជនជាប់ឃុំណាដែលបានចេញមកក្រៅរបងសុវត្ថិភាពវិញដោយវិធីណា ឬធ្វើអ្វីនោះ ខ្លួនមិនបានដឹងទេ។ លុះម៉ោងប្រហែល ៧ យប់ លោកអនុប្រធានទទួលផែនសន្តិសុខបានហៅខ្លួនឱ្យចូលទៅក្នុងបន្ទប់ ហើយនៅពេលដែលខ្លួនទៅដល់នៅលើតុឃើញ មានគ្រឿងញៀន ហើយខ្លួនបានសួរថា "មានរឿងអីមេ" គាត់ក៏បានប្រាប់ថា "មានគេឆ្លើយដាក់" នៅពេលនោះ ខ្លួនបាននិយាយថា ខ្លួនមិនដឹងអ្វីទេ គាត់ក៏បានតបវិញថាធ្វើតាមនីតិវិធីទៅ។ បន្ទាប់មកសមត្ថកិច្ចក៏បាននាំខ្លួនទៅស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ដើម្បីធ្វើការសាកសួរ។ នៅពេលមកដល់ស្នងការដ្ឋានម៉ោង

[redacted]

ប្រហែលជា ៨ យប់ នៅពេលនោះ ប៉ូលីសមិនបានសួរអ្វីច្រើនទេ គេថាហត់ណាស់ចាំព្រឹកចាំសួរទៀត។ ខ្លួនឆ្លើយតែការពិត ព្រោះខ្លួនមិនបានធ្វើអ្វីខុសនោះទេ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] កែវមុន្នី បានឆ្លើយនាពេលសវនាការថា៖ នៅថ្ងៃកើតហេតុនោះ មន្ត្រីពន្ធនាគារចំនួន ០៤ នាក់ រួមមានឈ្មោះ [redacted] ឌីម៉ង់ ,ឈ្មោះ [redacted] ប៉ក់ ,ឈ្មោះ [redacted] ភារម្យ និងឈ្មោះ [redacted] ចិត្ត បាននាំជនជាប់ឃុំចំនួន ០៣ នាក់ ដើម្បីយកសម្រាមទៅចោល។ លុះពេលចាក់សម្រាមចោលហើយ មុនចូលក្នុងរបងសុវត្ថិភាពវិញ ខ្លួនបានធ្វើការឆែកឆេរហើយ ឃើញថាមិនមានអ្វីទេ ទើបខ្លួនអនុញ្ញាតឱ្យជនជាប់ឃុំចូលវិញ។ លុះជនជាប់ឃុំបានចូលរបងសុវត្ថិភាពអស់ហើយ ស្រាប់តែជនជាប់ឃុំម្នាក់ឈ្មោះ [redacted] រិទ្ធី បានសុំខ្លួនចេញទៅក្រៅរបងសុវត្ថិភាព។ ពេលនោះ ខ្លួនបានសួរថា "ហ្អែងទៅណា" វាក៏ឆ្លើយថា "មេចិត្តហៅឱ្យទៅលាងចាន" នៅពេលនោះ ខ្លួនក៏បានអនុញ្ញាតឱ្យចេញ។ លុះបានប្រហែល ១០ នាទីក្រោយមក វាត្រឡប់មកវិញហើយវាប្រាប់ខ្លួនថា "អត់មានចានលាងផង" នៅពេលនោះ ខ្លួនក៏មានការសង្ស័យ ហើយឆែកឆេរនឹងចង្កេះខោមានដុំថង់ពណ៌សរុំស្កុតខ្មៅ។ បន្ទាប់មក ខ្លួនក៏បានរាយការណ៍ទៅលោក [redacted] ចាន់ដារ៉ា ហៅ ហុង អនុប្រធានពន្ធនាគារទទួលផែនសន្តិសុខ ហើយគាត់ក៏បានមកភ្លាមៗព្រោះនៅជិតគ្នា ហើយខ្លួនបានរៀបរាប់តាមដំណើររឿង រួចខ្លួនទៅយាមនៅរបងសុវត្ថិភាពវិញ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៉ក់ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ វេលាម៉ោងប្រហែលជា ១០ ព្រឹក ខ្លួន និងមន្ត្រីពន្ធនាគារចំនួន ០៣ នាក់ទៀត រួមមានឈ្មោះ ធន ឌីម៉ង់ ,ឈ្មោះ [redacted] ភារម្យ ,ឈ្មោះ [redacted] ចិត្ត បាននាំជនជាប់ឃុំចំនួន ០៣ នាក់ រួមមានឈ្មោះ [redacted] ចាន់ ,ឈ្មោះ [redacted] ប៊ុនហៀង និងឈ្មោះ [redacted] រិទ្ធី ដើម្បីយកសម្រាមទៅចាក់ចោល ដោយពួកខ្លួនជាអ្នកឃ្លាំមើល។ នៅពេលនោះ មន្ត្រីឈ្មោះ [redacted] ចិត្ត បានឱនរើសរបស់អ្វីមួយ តែខ្លួនមិនដឹងថាជាអ្វីនោះទេ ព្រោះគេនៅឆ្ងាយពីខ្លួនប្រហែល ៥០ ម៉ែត្រ ពេលនោះខ្លួនក៏មិនបានសួរនាំអ្វីដែរ។ នៅពេលចាក់សម្រាមហើយ ពួកខ្លួនបាននាំជនជាប់ឃុំចូលទៅក្នុងរបងសុវត្ថិភាពវិញ ហើយមន្ត្រីឈ្មោះ [redacted] កែវមុន្នី ជាអ្នកឆែកឆេរមុននឹងឱ្យជនជាប់ឃុំចូលខាងក្នុងវិញ នៅពេលឆែកឆេរមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ។ ក្រោយ [redacted] បញ្ជូនជនជាប់ឃុំចូលក្នុងរបងសុវត្ថិភាពវិញហើយ ពួកខ្លួនក៏បានទៅធ្វើការរៀងៗខ្លួនទៅ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ភារម្យ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ វេលាម៉ោងប្រហែលជា ១០ ព្រឹក ខ្លួន និងមន្ត្រីពន្ធនាគារចំនួន ០៣ នាក់ទៀត រួមមានឈ្មោះ [redacted] ឌីម៉ង់ ,ឈ្មោះ [redacted] ប៉ក់ និងឈ្មោះ [redacted] ចិត្ត បាននាំជនជាប់ឃុំចំនួន ០៣ នាក់ រួមមានឈ្មោះ [redacted] ចាន់ ,ឈ្មោះ [redacted] ប៊ុនហៀង និងឈ្មោះ [redacted] រិទ្ធី ដើម្បីយកសម្រាមទៅចាក់ចោល ដោយពួកខ្លួនជាអ្នកឃ្លាំមើល។ នៅពេលទៅដល់កន្លែងចាក់សម្រាមមន្ត្រីឈ្មោះ [redacted] ចិត្ត បានឱនរើសរបស់អ្វីម្យ៉ាងដាក់ក្នុងហោប៉ៅ តែខ្លួនមិនដឹងថាជាអ្វីនោះទេ ព្រោះគេនៅឆ្ងាយពីខ្លួនប្រហែល ២០ ម៉ែត្រ ពេលនោះខ្លួនក៏បានសួរទៅឈ្មោះ [redacted] ឌីម៉ង់ ថា "មិញគេរើសអីគេ" គាត់ក៏បានតបវិញថា "អត់ដឹងអីដែរ" នៅពេលនោះ

បង ឌីម៉ង់ ក៏បានសួរទៅឈ្មោះ [redacted] ចិត្ត ថា "អីគេមិញ" នៅពេលនោះឈ្មោះ [redacted] ចិត្ត មិនបានតបទេចំពោះឈ្មោះ [redacted] ចិត្ត លឺ ឬមិនលឺខ្លួនក៏មិនបានដឹងដែរ។ នៅពេលចាក់សម្រាមហើយ ពួកខ្លួនបាននាំជនជាប់ឃុំចូលទៅក្នុងរបងសុវត្ថិភាពវិញ ហើយមន្ត្រីឈ្មោះ [redacted] កែវមុន្នី ជាអ្នកឆែកឆេរមុននឹងឱ្យជនជាប់ឃុំចូលខាងក្នុងវិញ នៅពេលឆែកឆេរមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ។ ក្រោយពេលបញ្ជូនជនជាប់ឃុំចូលក្នុងរបងសុវត្ថិភាពវិញហើយ ពួកខ្លួនក៏បានទៅធ្វើការរៀងៗខ្លួនទៅ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ឌីម៉ង់ បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ វេលាម៉ោងប្រហែលជា ១០ ព្រឹក ខ្លួន និងមន្ត្រីពន្ធនាគារចំនួន ០៣ នាក់ទៀត រួមមានឈ្មោះ [redacted] ភារម្យ ,ឈ្មោះ [redacted] ប៉ក់ និងឈ្មោះ [redacted] ចិត្ត បាននាំជនជាប់ឃុំចំនួន ០៣ នាក់ រួមមានឈ្មោះ [redacted] ចាន់ ,ឈ្មោះ [redacted] ប៊ុនហៀង និងឈ្មោះ [redacted] រិទ្ធី ដើម្បីយកសម្រាមទៅចាក់ចោល ដោយពួកខ្លួនជាអ្នកឃ្លាំមើល។ នៅពេលទៅដល់កន្លែងចាក់សម្រាម មន្ត្រីឈ្មោះ [redacted] ចិត្ត បានឱនរើសរបស់អ្វីម្យ៉ាង តែខ្លួនមិនដឹងថាជាអ្វីនោះទេ ព្រោះគេនៅឆ្ងាយពីខ្លួនប្រហែល ១០០ ម៉ែត្រ ពេលនោះខ្លួនក៏បានសួរទៅឈ្មោះ [redacted] ចិត្ត ថា "អូនមិញរើសអីគេ" គាត់ក៏បានតបវិញថា "អត់មានអីទេ" នៅពេលនោះខ្លួនក៏មិនបានសួរនាំអ្វីទៀតដែរ។ នៅពេលចាក់សម្រាមហើយ ពួកខ្លួនបាននាំជនជាប់ឃុំចូលទៅក្នុងរបងសុវត្ថិភាពវិញ ហើយមន្ត្រីឈ្មោះ [redacted] កែវមុន្នី ជាអ្នកឆែកឆេរមុននឹងឱ្យជនជាប់ឃុំចូលខាងក្នុងវិញ នៅពេលឆែកឆេរមិនមានអ្វីគួរឱ្យកត់សម្គាល់ទេ។ ក្រោយពេលបញ្ជូនជនជាប់ឃុំចូលក្នុងរបងសុវត្ថិភាពវិញហើយ ពួកខ្លួនក៏បានទៅធ្វើការរៀងៗខ្លួនទៅ។

-តាមចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌លោក [redacted] សារិត បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ ខ្លួនបានទទួលបញ្ជាពីថ្នាក់លើណែនាំឱ្យចុះទៅពន្ធនាគារខេត្តប៉ៃលិន ដើម្បីចុះអនុវត្តការងារទាក់ទងនឹងបទល្មើសគ្រឿងញៀន នៅពេលនោះ ខ្លួនបានចុះទៅអនុវត្តមានគ្នាចំនួន ០៤ នាក់រួមទាំងខ្លួន ហើយនៅពេលទៅដល់ពន្ធនាគារខេត្តប៉ៃលិនមានលោកប្រធានពន្ធនាគារ ,អនុប្រធានពន្ធនាគារ និងមន្ត្រីពន្ធនាគារម្នាក់ទៀតដែលមានវត្តមាននៅទីនោះ។ នៅពេលទៅដល់ ខ្លួនបានធ្វើការដកហូតថ្នាំញៀនចំនួន ០១ កញ្ចប់ធំជារបស់ឈ្មោះ [redacted] រិទ្ធី ,ទូរស័ព្ទស៊ិចចុចពិលចំនួន ០១ គ្រឿង និងរថយន្តម៉ាក PRIUS ចំនួន ០១ គ្រឿង ជារបស់ឈ្មោះ [redacted] ចិត្ត ។ ក្រោយទទួលបញ្ជាពីថ្នាក់លើខ្លួនបាននាំជនសង្ស័យឈ្មោះ [redacted] ចិត្ត ទៅស្នងការដ្ឋាននគរបាលខេត្តប៉ៃលិន ដើម្បីធ្វើការសាកសួរតាមនីតិវិធីច្បាប់។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ហុង បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២១ ខ្លួនមិនបាននៅក្នុងហេតុការណ៍ដែលជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី និងជនជាប់ឃុំផ្សេងទៀត យកសម្រាមទៅចាក់ចោលនោះទេ។ ខ្លួនដឹងថាឈ្មោះ [redacted] រិទ្ធី ពាក់ព័ន្ធនឹងថ្នាំញៀន នៅពេលដែលឈ្មោះ [redacted] កែវមុន្នី បានបោះដៃមកខ្លួន ក្រោយពេលដែលគាត់ឆែកឃើញថ្នាំញៀននៅលើខ្លួនរបស់ជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី។ នៅពេលទទួលបានព័ត៌មាននេះ ខ្លួនបាន

ហោ ពិសិទ

រាយការណ៍ទៅប្រធានពន្ធនាគារខេត្តប៉ៃលិន។ នៅពេលធ្វើការសាកសួរចម្លើយមានវត្តមានខ្លួន លោក[redacted] ទី ,លោក[redacted] វិចិត្រ ,លោកប្រធានពន្ធនាគារ និងជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី ។ ក្នុងការសួរចម្លើយនោះមិនមានមេធាវី ឬភ្នាក់ងារសង្គមកិច្ចអមជនជាប់ឃុំនោះទេ។ នៅពេលសួរចម្លើយលោកប្រធានពន្ធនាគារជាអ្នកសួរ ចំណែកខ្លួនក៏បានសួរខ្លះៗដែរ។ ចំពោះសំណួរនាំមុខដែលនិយាយថា "ថ្នាំញៀននឹងមានគេឃើញឯងទៅយកពីឈ្មោះ [redacted] ចិត្ត ហ្អែងយកថ្នាំញៀននឹងពីឈ្មោះ [redacted] ចិត្ត មែនអត់?" ត្រង់សំណួរបែបនេះ គឺមិនមានទេ គ្រាន់តែឱ្យគាត់រៀបរាប់ពីហេតុការណ៍ដែលបានកើតឡើងតែប៉ុណ្ណោះ។ នៅពេលសួរចម្លើយជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី ថាយកថ្នាំញៀនពីណា? វាក៏ឆ្លើយរៀបរាប់ថាថ្នាំញៀននោះបានមកពីឈ្មោះ [redacted] ចិត្ត ហើយវាក៏មួរនឹងចង្កេះខោ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ថាន់ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរមានចម្លើយថា៖ កាលពីថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០២១ វេលាពេលព្រឹក ខ្លួន ,ឈ្មោះ [redacted] ប៊ុនហៀង (ពេលនេះគាត់ចេញពីពន្ធនាគារហើយ) និងឈ្មោះ [redacted] រិទ្ធី បានរុញរទេះដឹកសម្រាមយកទៅចាក់ចោលនៅក្រោយរបងសុវត្ថិភាព នៅពេលនោះមានមន្ត្រីពន្ធនាគារចំនួន ០៤ នាក់ មិនស្គាល់ឈ្មោះបានដើរឃ្លាំមើលពួកខ្លួនទាំងពេលរុញទៅនិងពេលរុញមក។ នៅពេលនោះឈ្មោះ [redacted] រិទ្ធី ជាអ្នកអូសរទេះ ចំណែកឈ្មោះ [redacted] ប៊ុនហៀង និងរូបខ្លួនជាអ្នករុញរទេះ ហើយខ្លួនមិនបានឃើញឈ្មោះ [redacted] រិទ្ធី រើសអ្វីទេ ហើយចំពោះមន្ត្រីពន្ធនាគារចំនួន ០៤ នាក់ ដែលដើរតាមឃ្លាំមើលខ្លួននោះ មិនបានដើរមកជិតខ្លួនទេ ហើយក៏មិនបាននិយាយប្រាស្រ័យទាក់ទងនឹងពួកខ្លួនទាំងបីដែរ។ ពេលរុញរទេះទៅចាក់សម្រាម និងពេលមកវិញ ខ្លួនមិនឃើញមានអ្វីប្លែកទេ។ នៅពេលចូលច្រកសុវត្ថិភាពវិញ ខ្លួនត្រូវបានមន្ត្រីពន្ធនាគារឈ្មោះ នីឆែកឆេរ ហើយរកមិនឃើញមានអ្វីទេ ក៏អនុញ្ញាតឱ្យចូលទៅខាងក្នុងវិញ។ ចំណែកឈ្មោះ [redacted] រិទ្ធី ចូលក្រោយខ្លួន ហើយខ្លួនក៏មិនបានដឹងថាគាត់សុំចេញទៅក្រៅវិញដែរ។ ខ្លួនមិនបានដឹងរឿងអ្វីទេ ខ្លួនដឹងរឿងតែប៉ុណ្ណឹង។

[redacted] -តាមចម្លើយរបស់ឈ្មោះ [redacted] ព្រីង បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរមានចម្លើយថា៖ ចំពោះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ ខ្លួនដាក់ច្បាប់ ខ្លួនមិនបានបម្រើការងារទេ គឺខ្លួនបានសុំច្បាប់ដោយផ្ទាល់មាត់ទៅលោកប្រធានពន្ធនាគារខេត្តប៉ៃលិន។ ចំពោះឈ្មោះ [redacted] ចិត្ត គាត់ជាមន្ត្រីល្អ គាត់និយាយស្ដីមានការចេះដឹង។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សារ៉ូ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២១ ខ្លួនមិនបាននៅក្នុងហេតុការណ៍ដែលជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី និងជនជាប់ឃុំផ្សេងទៀត យកសម្រាមទៅចាក់ចោលនោះទេ។ ខ្លួនដឹងថាឈ្មោះ [redacted] រិទ្ធី ពាក់ព័ន្ធនឹងថ្នាំញៀន នៅពេលដែលខ្លួនចូលរួមសួរចម្លើយពាក់ព័ន្ធនឹងឈ្មោះ [redacted] រិទ្ធី ។ នៅពេលសួរចម្លើយនោះខ្លួនមិនបានឃើញ ឬលឺមន្ត្រីពន្ធនាគារធ្វើការសម្លុត ឬគម្រាមកំហែងទៅលើឈ្មោះ [redacted] រិទ្ធី នោះទេពេលនោះខ្លួនគ្រាន់តែចូលរួមនីតិវិធីសួរចម្លើយប៉ុណ្ណោះ ខ្លួនមិនបានសួរអ្វីឡើយ។ ចំពោះសំណួរនាំមុខ

ដែលនិយាយថា "ថ្នាំញៀននឹងមានគេឃើញឯងទៅយកពីឈ្មោះ [redacted] ចិត្ត ហ្វែងយកថ្នាំញៀននឹងពីឈ្មោះ ងៀ ចិត្ត មែនអត់?" ត្រង់ចំណុចនេះ គឺមិនមានទេ គ្រាន់តែឱ្យគាត់រៀបរាប់ហេតុការណ៍ ដែលបានកើតឡើងតែប៉ុណ្ណោះ។ នៅថ្ងៃកើតហេតុនោះ មិនមានអ្នកណាឃើញថាឈ្មោះ [redacted] រិទ្ធី ទៅជួយការងារ ឬយករបស់អ្វីពីឈ្មោះ [redacted] ចិត្ត នោះទេ។ តាមការអះអាងរបស់ឈ្មោះ [redacted] រិទ្ធី ដែលនិយាយថាទៅជួយលាងចានឱ្យឈ្មោះ [redacted] ចិត្ត នោះ គឺមិនមានអ្នកណាស្នើសុំឱ្យចេញនោះទេ គឺឈ្មោះ [redacted] រិទ្ធី និយាយតែខ្លួនឯងប៉ុណ្ណោះ។ ចំពោះឈ្មោះ [redacted] ចិត្ត គាត់ជាមន្ត្រីល្អធម្មតា។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ទី បានឆ្លើយនៅដំណាក់កាលសវនាការថា៖ ខ្លួនមានវត្តមាននៅពេលសួរចម្លើយជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី ប៉ុណ្ណោះ ដោយមានវត្តមានលោក [redacted] វិចិត្រ ជាអនុប្រធានពន្ធនាគារ ,លោក [redacted] ចាន់ដារ៉ា ហៅ ហុង ជាអនុប្រធានពន្ធនាគារ ,លោក [redacted] សារ៉ូ ជាអនុប្រធានពន្ធនាគារ និងលោក [redacted] ទី ជាប្រធានពន្ធនាគារខេត្តប៉ៃលិន ជាអ្នកធ្វើការសាកសួរ ចំណែកខ្លួនជាអ្នកធ្វើកំណត់ហេតុ។ នៅពេលធ្វើការសួរចម្លើយជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី នៅពេលនោះមិនមានអ្នកណាសម្លុត ឬគម្រាមជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី នោះទេ គឺគេឆ្លើយដោយខ្លួនឯងធម្មតា។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបញ្ចប់ការដេញដោល នៅពេលនេះឃើញថាអង្គហេតុប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ នៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កម្លាំងប្រឆាំងគ្រឿងញៀននៃអធិការដ្ឋាននគរបាលក្រុងប៉ៃលិន បានធ្វើការបង្ក្រាបបទល្មើសជាក់ស្តែង រក្សាទុក ,ជួញដូរ ,ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០២ នាក់ រួមមានឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ១៦ ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ចិត្ត ភេទប្រុស អាយុ ២៨ ឆ្នាំ ជាតិខ្មែរ និងបានធ្វើការឆែកឆេរលើទណ្ឌិតឈ្មោះ [redacted] រិទ្ធី ឃើញថ្នាំញៀនចំនួន ០១ កញ្ចប់ធំរុំដោយស្កុតពណ៌ខ្មៅទម្ងន់ ៦៧,៣៥ ក្រាម (ថ្នាំសុទ្ធ) បម្រុងយកចូលទៅក្នុងពន្ធនាគារ។ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ ,រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់ពិតប្រាកដមែន ដោយជននេះ មានចេតនាយកថ្នាំញៀនចំនួន ០១ ដុំធំ យកចូលពន្ធនាគារ ប៉ុន្តែត្រូវបានមន្ត្រីពន្ធនាគារឆែកឆេរឃើញ ហើយចំពោះថ្នាំញៀនចំនួន ០១ ដុំ នោះ មានការជាប់ពាក់ព័ន្ធជាមួយជនជាប់ចោទឈ្មោះ [redacted] ចិត្ត ផងដែរ។ ហេតុដូច្នេះតំណាងអយ្យការស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា និងសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបញ្ចប់ការដេញដោលឃើញថា កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២១ កូនក្តីរបស់ខ្លួនបានយកសម្រាមទៅចោល ស្រាប់តែឃើញប្រអប់មួយដែលមានរុំដោយថង់ខ្មៅក៏បានរើសយកមកដាក់នៅចង្កេះខោ ហើយកូនក្តីរបស់ខ្លួនមិនដឹងថារបស់នោះជារបស់អ្វីនោះទេ គ្រាន់តែសង្ស័យថាជាទូរស័ព្ទទើបរើសយកមក ប៉ុន្តែនៅ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ប៉ៃលិន,ថ្ងៃទី១៧...ខែ០៨...ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

ពេលដែលមន្ត្រីពន្ធនាគារឆែកមើលប្រអប់នោះ ទើបដឹងថាវាជាគ្រឿងញៀន។ ខ្លួនសូមបញ្ជាក់បន្ថែមទៀតថា កូនក្តីរបស់ខ្លួនមិនបានដឹងថាប្រអប់នោះមានរបស់អ្វីទេ គឺកូនក្តីរបស់ខ្លួនស្មានថាជាទូរស័ព្ទ ឬរបស់មានតម្លៃ ទើបរើសយកមកទុកតែមិននឹកស្មានថាជាគ្រឿងញៀននោះឡើយ បើដឹងថាជាគ្រឿងញៀនកូនក្តីរបស់ខ្លួនក៏មិនយកចូលទៅក្នុងពន្ធនាគារដែរ ព្រោះដឹងថានៅពន្ធនាគារគេតឹងរឹងណាស់ បើចូលមកគេច្បាស់ជាឆែកឆេរជាមុនហើយ។ ហេតុដូច្នេះ ឃើញថាកូនក្តីរបស់ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ហើយកូនក្តីរបស់ខ្លួនក៏មិនមានល្បិចកិច្ចកលចង់កុហកតុលាការនោះដែរ។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ខ្លួនស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាលើកលែងការចោទប្រកាន់ឱ្យកូនក្តីរបស់ខ្លួន។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិត្ត បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងកាត់តាមការពិនិត្យលើអង្គហេតុ និងក្រោយពីឆ្លងកាត់ការពិភាក្សាដេញដោលរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ត្រូវបានចោទប្រកាន់តាមចម្លើយរបស់ជនជាប់ឃុំឈ្មោះ [redacted] រិទ្ធី នៅពេលសួរចម្លើយនៅពន្ធនាគារ។ នៅក្នុងអង្គសវនាការទាំងមូលបានលឺហើយថាការឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត បែបនេះគឺដោយសារមានសំណួរនាំមុខពីលោកអនុប្រធានពន្ធនាគារខេត្តប៉ៃលិន ដោយបានសួរសំណួរបំភ័យថាបើមិនឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត ទេនឹងឱ្យជាប់ទោសពីម្ភៃទៅសាមសិបឆ្នាំ។ ការសួរសំណួរបែបនេះគឺជាការសួរបំភ័យ ហើយម្យ៉ាងទៀតការសួរចម្លើយគ្មានមេធាវីអម ឬអង្គការចាត់តាំងណាមួយនោះទេ។ ការស៊ើបអង្កេត និងការស៊ើបសួរកន្លងមកតាមរយៈចៅក្រមស៊ើបសួររហូតមកដល់ពេលនេះ គឺពុំមានតម្រុយ ឬភស្តុតាងណាមួយដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] ចិត្ត នោះទេ ក្រៅពីការចោទប្រកាន់ទៅតាមចម្លើយរបស់ឈ្មោះ [redacted] រិទ្ធី ឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត ឡើយ។ ការចោទប្រកាន់ដោយគ្មានភស្តុតាង និងសំអាងហេតុគ្រប់គ្រាន់ដាក់បន្ទុកបែបនេះ គឺស្ថិតនៅក្នុងវិមតិសង្ស័យ ហេតុដូច្នេះសូមឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចលើកលែងការចោទប្រកាន់លើឈ្មោះ [redacted] ចិត្ត និងសម្រេចដោះលែងឈ្មោះ [redacted] ចិត្ត ឱ្យមានសេរីភាពវិញ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត ។

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] កែវមុន្នី ។

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] ប៉ក់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] ភារម្យ ។

ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted] ទី ។

ក្រោយពីបានស្តាប់ចម្លើយរបស់សមត្ថកិច្ចឈ្មោះ [redacted] សារិត ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ហុង ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

[redacted]

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]ចាន់ ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សារុ ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]ព្រើង ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិត្ត ។

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាយ៉ាងល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ ពិតជាមានអំពើ ជួញដូរ ,រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ១៦ ឆ្នាំ ជនជាតិ និងសញ្ជាតិខ្មែរ ពិតប្រាកដមែន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី និងការពិនិត្យភស្តុតាងផ្សេងៗ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ពិតជាមានចេតនាយកថ្នាំញៀនដែលខ្លួនរើសបានចូលក្នុងពន្ធនាគារពិតប្រាកដមែន បើទោះបីជាដឹងថាវាជាវត្ថុខុសច្បាប់ក៏ដោយ ប៉ុន្តែដោយឃើញថា ជននេះបានឆ្លើយសារភាពថា ការដែលឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត ក៏ព្រោះតែមានគេសួរគម្រាមកំហែងបំភ័យខ្លួន ទើបខ្លួនឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត ទៅ តែតាមការពិតឈ្មោះ [redacted] ចិត្ត គឺគេមិនបានដឹងរឿងអ្វីនោះទេ ហើយខ្លួនស្តាយនូវកំហុសរបស់ខ្លួនដែលឆ្លើយដាក់មនុស្សមិនដឹងរឿងអ្វីសោះឱ្យមកជាប់ពាក់ព័ន្ធជាមួយខ្លួន ហើយជននេះបានសារភាពទៀតថា ខ្លួនយកប្រអប់ខ្មៅចូលពន្ធនាគារ គឺជាគំនិតរបស់ខ្លួនទាំងស្រុង មិនមែនឈ្មោះ [redacted] ចិត្ត ជាអ្នកបញ្ជាឱ្យទៅយកនោះទេ ហើយការដែលឆ្លើយថា សុំទៅលាងចានឱ្យឈ្មោះ [redacted] ចិត្ត គឺជាគំនិតរបស់ខ្លួនទាំងអស់។ យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី មានការភ្ញាក់រលឹកដឹងនូវកំហុសរបស់ខ្លួន ម្យ៉ាងវិញទៀតជនជាប់ចោទជាអនីតិជនផង គប្បីតុលាការពិចារណាអំពីស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ដោយផ្អែកលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ។

៣-តាមចម្លើយរបស់ឈ្មោះ [redacted] ចិត្ត និងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ព្រមទាំងចម្លើយរបស់សាក្សី ឃើញថា គ្មានភស្តុតាងណាមួយ ដើម្បីដាក់បន្ទុកដល់ជនជាប់ចោទឈ្មោះ [redacted] ចិត្ត នោះទេ ដែលធ្វើឱ្យមានវិមតិសង្ស័យចំពោះជនជាប់ចោទឈ្មោះ [redacted] ចិត្ត ហើយម្យ៉ាងវិញទៀតជនជាប់ចោទឈ្មោះ [redacted] រិទ្ធី បានឆ្លើយសារភាពថា ឈ្មោះ [redacted] ចិត្ត គឺមិនបានពាក់ព័ន្ធនៅក្នុងរឿងនេះទេ ការដែលខ្លួនឆ្លើយដាក់ឈ្មោះ [redacted] ចិត្ត គឺព្រោះតែមានគេសួរសម្លុតគម្រាមខ្លួនឱ្យឆ្លើយប៉ុណ្ណោះ។ ក្រោយពីធ្វើការស៊ើបអង្កេត និងស៊ើបសួរកន្លងមកឃើញថាក៏គ្មានភស្តុតាង ឬសាក្សីណាមួយបានឃើញជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ទៅយកថ្នាំញៀនពីឈ្មោះ [redacted] ចិត្ត នោះដែរ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី១៧ ខែ០៨ ឆ្នាំ២០២២



ក្រឡាបញ្ជី

[redacted]

៤-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការឃើញថា តំណាងអយ្យការរក្សានូវការចោទប្រកាន់របស់ខ្លួននៅដដែល។ ហេតុដូច្នេះ គប្បីតុលាការធ្វើការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទដោយផ្អែកទៅលើភស្តុតាងផ្សេងៗ នៅពេលដែលតុលាការរកឃើញថាជនជាប់ចោទមានពិរុទ្ធភាព ។

៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធី (អត្តសញ្ញាណដូចខាងលើ) បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ដែលច្បាប់កំណត់ថាជាបទល្មើស។ ដូចនេះ ជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់។

៦-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី (អត្តសញ្ញាណដូចខាងលើ) ពីបទ ជួញដូរ ,រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែគប្បីសម្រេចផ្តល់ស្ថានសម្រាលដល់ជននេះ ដោយផ្អែកលើបញ្ញត្តិមាត្រា ៩៣ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

៧- គ្មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចិត្ត ពីបទ ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុង ខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះទេ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចិត្ត តាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ។

៨-វត្ថុតាងមាន៖ ម្សៅក្រាមពណ៌សថ្លា (មេតំហ្វេតាមីន) ចំនួន ០១ កញ្ចប់ធំ មានទម្ងន់ ៦៩,៥១ ក្រាម (ថ្លឹងទាំងថង់) និងទូរស័ព្ទអ៊ិនចុចពិលចំនួន ០១ គ្រឿង គប្បីតុលាការរឹបអូសបំផ្លាញចោលតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-អំពីទណ្ឌកម្ម៖ កម្រិតនៃទណ្ឌកម្មដែលមានកំណត់តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនមានកម្រិតឱ្យផ្តន្ទាទោសពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យជាប្រាក់ពី ១០,០០០ ,០០០ (ដប់លាន) រៀល ទៅ ២០,០០០,០០០ (ម្ភៃលាន) រៀល ។ ដូច្នេះគប្បីតុលាការពិចារណាអំពីការប្រកាសទោសក្នុងកម្រិតដែលមានកំណត់នេះ ។

## ហេតុដូច្នេះ-តុលាការ

## សម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ១៦ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥,០០០,០០០ (ប្រាំលាន) រៀល ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ប៉ៃលិន ថ្ងៃទី១២ ខែ០៨ ឆ្នាំ២០២៤



ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

ពីបទ៖ ជួញដូរ ,រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២-ឱ្យរួចខ្លួនពីបទចោទលើជនជាប់ចោទឈ្មោះ [redacted] ចិត្ត ភេទប្រុស អាយុ ២៨ ឆ្នាំ ជាតិខ្មែរ

ពីបទ ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងពន្ធនាគារខេត្តប៉ៃលិន ស្ថិតនៅភូមិទឹកចេញ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន កាលពីអំឡុងខែធ្នូ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមបញ្ញត្តិមាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ។

៣-រឹបអូសម្សៅក្រាមពណ៌សថ្លា (មេតំហ្វេតាមីន) ចំនួន ០១ កញ្ចប់ធំ មានទម្ងន់ ៦៩,៥១ ក្រាម (ថ្លឹងទាំងថង់) និងទូរស័ព្ទអ៊ិនចុចពិលចំនួន ០១ គ្រឿង បំផ្លាញចោលតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ និងប្រកាសជាអសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធី និងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិត្ត នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានឃើញ**

ប៉ៃលិន,ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃ សុក្រ ០៣ រោច ខែជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ប៉ៃលិន,ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ប៉ៃលិន ថ្ងៃទី ១៦ ខែ ០៨ ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]